# វិធីទទួលបានការធ្វើតេស្តជំងឺ COVID-19

## មានវិធីជាច្រើនដើម្បីទទួលបានការធ្វើតេស្តជំងឺ COVID-19 នៅក្នុងខោនធី LA។

**ទូរស័ព្ទទៅគ្រូពេទ្យរបស់អ្នក។**

- សូមពិពណ៌នាអំពីរោគសញ្ញារបស់អ្នកដើម្បីសម្រេចចិត្តថាតើអ្នកត្រូវការធ្វើតេស្តដែរឬទេ។
- សូមរៀបចំជាមួយគ្រូពេទ្យរបស់អ្នកដើម្បីកំណត់ពេលណាត់ជួប។

**ទាក់ទងទៅសាលារៀន ឬម្ចាស់អាជីវកម្មរបស់អ្នក។**

- សាលារៀននៅក្នុងតំបន់ និងកន្លែងធ្វើការជាច្រើនផ្តល់ការធ្វើតេស្តដោយឥតគិតថ្លៃដល់សិស្ស និងបុគ្គលិក។

**ទៅកាន់ទីតាំងធ្វើតេស្តរបស់ខោនធី LA ដែលនៅជិតអ្នក។**

- សូមទូរស័ព្ទទៅលេខ 211 ផ្ញើសារជាអក្សរទៅលេខ 844-833-1334 ឬចូលទៅកាន់គេហទំព័រ covid19.lacounty.gov/testing ដើម្បីស្វែងរកទីតាំងធ្វើតេស្តប្រភេទ PCR ដោយឥតគិតថ្លៃដែលនៅជិតអ្នក។
- ការធ្វើតេស្តជំងឺ COVID-19 គឺមិនគិតថ្លៃនៅគ្រប់ទីតាំងដែលដំណើរការដោយខោនធី LA ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍ ឬការមានធានារ៉ាប់រងឡើយ។
- មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យធ្វើការណាត់ជួបជាមុន។

**ប្រើប្រាស់កម្មវិធីធ្វើតេស្តនៅតាមផ្ទះ (Home Test Collection Program)។**

- សូមចុះឈ្មោះដើម្បីទទួលបានឧបករណ៍ធ្វើតេស្តប្រភេទ PCR ដោយឥតគិតថ្លៃដែលអាចផ្ញើទៅអ្នកនៅផ្ទះតាមរយៈ៖ covid19.lacounty.gov/testing/home-test-collection-program/។
- សូមធ្វើតេស្តរបស់អ្នកនៅផ្ទះ ហើយផ្ញើវាទៅវិញ ដើម្បីទទួលបានលទ្ធផលរបស់អ្នក។

**ប្រសិនបើអ្នកមានរោគសញ្ញា ឬអ្នកបានប៉ះពាល់ទៅនឹងមេរោគ សូមទទួលយកឧបករណ៍ធ្វើតេស្តជំងឺ COVID-19 ដោយឥតគិតថ្លៃឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន!**



**ជៀសវាងការក្លែងបន្លំចំពោះធ្វើតេស្តជំងឺ COVID-19៖**

ប្រសិនបើអ្នកគិតថាអ្នកបានរកឃើញទីតាំងធ្វើតេស្តជំងឺ COVID-19 បណ្តោះអាសន្នដែលក្លែងក្លាយ ឬបានទិញឧបករណ៍ធ្វើតេស្តជំងឺ COVID-19 នៅផ្ទះដែលក្លែងក្លាយ សូមរាយការណ៍ទៅនាយកដ្ឋានកិច្ចការអតិថិជន និងជំនួញ តាមរយៈ គេហទំព័រ bit.ly/DCBAHelp ឬទូរស័ព្ទទៅកាន់លេខ (800) 593-8222។

**ចំណាយសម្រាប់ឧបករណ៍ធ្វើតេស្តប្រភេទ antigen នៅផ្ទះដែលរហ័ស។**

- ឧបករណ៍ធ្វើតេស្តដែលរហ័សអាចទិញបាននៅតាមឱសថស្ថាន ហាងលក់ដូរ និងទីតាំងផ្សេងទៀតដែលនៅជិតអ្នក។
- ប្រសិនបើអ្នកចំណាយប្រាក់ទិញឧបករណ៍ធ្វើតេស្តដែលរហ័សនេះ សូមរក្សាទុកវិក័យប័ត្ររបស់អ្នក។ អ្នកប្រហែលជាអាចទទួលបានប្រាក់សំណងតាមរយៈធានារ៉ាប់រងសុខភាពរបស់អ្នក។

**ទៅកាន់ទីតាំងធ្វើតេស្តដែលមិនមែនជារបស់ខោនធី។**

- ទីតាំងខ្លះគឺគ្រប់គ្រងដោយក្រុមហ៊ុនឯកជន ប្រព័ន្ធថែទាំសុខភាពឯកជន ឬទីក្រុងក្នុងតំបន់។
    - ទីតាំងទាំងនេះមិនត្រូវបានដំណើរការដោយ ឬភ្ជាប់ជាមួយខោនធី LA ទេ។
- ទីតាំងទាំងនេះអាចនឹងត្រូវឱ្យអ្នកបង់ប្រាក់សម្រាប់ការធ្វើតេស្ត។ សូមធ្វើការសាកសួរ ថាតើមានការគិតថ្លៃ ឬថ្លៃសេវាកម្មបន្ថែមដែរឬទេ។
- ទីតាំងទាំងនេះក៏ប្រហែលជាអាចស្នើសុំព័ត៌មានដូចជាប័ណ្ណសម្គាល់ខ្លួនដែលចេញដោយរដ្ឋាភិបាល ឬធានារ៉ាប់រងផងដែរ។